# សេចក្តីប្រកាសព័ត៌មាន

# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៧

## ដំណើរទស្សនកិច្ចនាវាចំនួន 3 គ្រឿងរបស់កងនាវាស្វ័យការពារជើងទឹកជប៉ុន មកកាន់ព្រះរាជាណាចក្រកម្ពុជានៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ ចាប់ពីថ្ងៃ ច័ន្ទ ទី ១៣ ដល់ ថ្ងៃ ព្រហស្បតិ៍ ទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧

១-នាវាចំនួន ៣ គ្រឿងរបស់កងស្វ័យការពារជើងទឹកជប៉ុនដែលមានឈ្មោះថា **“ម៉ាគីណាមី” “អាសាយុគី” និង “ស៊ីម៉ាយុគី”** ដឹកនាំដោយ វរនាវីឯក កាវ៉ាគូប៊ូ ម៉ាសាហ៊ីកូ មេបញ្ជាការកងពលធំអមការពារលេខ ១៣ នៃកងនាវាស្វ័យការពារជើងទឹកជប៉ុន នឹងមកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាចាប់ពីថ្ងៃទី ១៣ ដល់ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១៧ ក្នុងឱកាសនៃដំណើរហ្វឹកហ្វឺនលើលំហសមុទ្រ។ គោលបំណងនៃដំណើរទស្សនកិច្ចនេះ គឺដើម្បីពង្រឹងទំនាក់ទំនងមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជាតាមរយៈកម្មវិធីផ្លាស់ប្តូរផ្សេងៗ ក៏ដូចជាដើម្បីផ្តល់ឱកាសអោយនាយនាវិកចំនួន ១១០ នាក់ ដែលទើបបានបញ្ចប់ការសិក្សា បានស្វែងយល់អំពីវប្បធម៌ និងវិស័យយោធានៅព្រះរាជាណាចក្រកម្ពុជា ។

២-ក្នុងអំឡុងពេលទស្សនកិច្ចនៅកម្ពុជា វរនាវីឯក កាវ៉ាគូប៊ូ ម៉ាសាហ៊ីកូ មានគំរោងធ្វើទស្សនកិច្ចមកកាន់រាជធានីភ្នំពេញ ដើម្បីជួបសំដែងការគួរសមជាមួយមេបញ្ជាការកងទ័ពជើងទឹកកម្ពុជានៅថ្ងៃទី ១៤ ខែ កុម្ភៈ។ វរនាវីឯក កាវ៉ាគូប៊ូ ម៉ាសាហ៊ីកូ ក៏នឹងធ្វើទស្សនកិច្ចនៅមូលដ្ឋានជើងទឹករាម សាលាខេត្តព្រះសីហនុ និងកំពង់ផែស្វយ័តក្រុងព្រះសីហនុនៅថ្ងៃទី ១៣ ខែ កុម្ភៈ ។

៣-ពិធីស្វាគមន៍ការមកដល់ នៃកងស្វ័យការពារជើងទឹកជប៉ុន នឹងប្រារព្ធឡើងនៅថ្ងៃទី ១៣ ខែ កុម្ភៈ នាវេលាម៉ោង ១០:៣០ ព្រឹកនៅឯផែចាស់ នៃកំពង់ផែក្រុងព្រះសីហនុ៕

---

ស្ថានទូតជប៉ុន អាស័យដ្ឋានលេខ 194 មហាវិថីព្រះនរោត្តម ទូរស័ព្ទ: (023) 217-161/4 ទូរសារ: (023) 216 162
អ៊ីម៉ែល: Info.jpn@pp.mofa.go.jp វេបសាយផ្លូវការ : www.kh.emb-japan.go.jps